ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៣០៣ សហវ.ពដ

# ប្រកាស
## ស្តីពី
## ការទទួលខុសត្រូវរបស់អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករ ចំពោះប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ដែលសហគ្រាសត្រូវបង់

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ និងព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតំរូវនៃច្បាប់ស្តីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០០៩ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញប្រកាសលេខ ០៧៤ ប្រ.កសហវ.ពដ ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ ១៩៩៨ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៏វិធានការតឹងទារបំណុលពន្ធ ។
- បានឃើញការចាំបាច់របស់នាយកដ្ឋានពន្ធដារ

## សម្រេច ៖

**ប្រការ ១.–** ប្រាក់ពន្ធត្រូវដល់កំណត់ និងត្រូវបង់នៅក្នុងរយៈពេលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតម្រូវឱ្យធ្វើការដាក់លិខិតប្រកាសសារពើពន្ធ ។

**ប្រការ ២.–** ១- ក្នុងករណីដែលប្រាក់ពន្ធរបស់អ្នកជាប់ពន្ធត្រូវបានបង់តាមវិធីកាត់ទុក ហើយអ្នកជាប់ពន្ធគ្មានកាតព្វកិច្ចធ្វើប្រកាសសារពើពន្ធទេនោះ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ គឺជាការកំណត់ចំនួនប្រាក់ពន្ធដែលបានកាត់ទុកនៅក្នុងឆ្នាំប្រតិទិន ។

២- ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចត្រូវដាក់លិខិតប្រកាសសារពើពន្ធ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកបានគណនានៅលើលិខិតប្រកាសសារពើពន្ធដែលដាក់ជូនរដ្ឋបាលសារពើពន្ធ ។

៣- ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ ប៉ុន្តែមិនបានធ្វើលិខិតប្រកាស មិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងទៀតតាមការតម្រូវ ឬមិនផ្តល់ពត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ ដើម្បីកំណត់ពន្ធឱ្យបានត្រឹមត្រូវ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធជាឯកតោភាគី ដែលរដ្ឋបាលសារពើពន្ធបានធ្វើ និង បានប្រគល់ឱ្យនោះ ។

**ប្រការ ៣.–** ១- ដូចមានចែងក្នុងមាត្រា ១០៨ នៃច្បាប់ស្តីពីសារពើពន្ធ ដូចមានក្នុងយោងខាងលើ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសណាមួយដឹងឮ ឬមានចេតនាធ្វើឱ្យសហគ្រាស មិនរាយការណ៍ មិនបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ ឬរាយការណ៍បន្ថយនូវប្រាក់ពន្ធ ដោយរំលោភទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬមិនឱ្យបង់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករទាំងនោះ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធដែលត្រូវបង់ ។

២- រដ្ឋបាលសារពើពន្ធ មានសិទ្ធិអនុវត្តវិធានការតឹងទារប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ដែលសហគ្រាសត្រូវបង់តាមការតំរូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ដូចដែលត្រូវអនុវត្តចំពោះសហគ្រាសដែរ ។

**ប្រការ ៤.–** វិធានការតឹងទាររបស់រដ្ឋបាលសារពើពន្ធ រួមមាន៖

១- ការតម្រូវឱ្យបុគ្គលនានា រួមមានរូបវន្តបុគ្គល នីតិបុគ្គល អង្គការ ស្ថាប័នរដ្ឋនានា... ដែលមានកាតព្វកិច្ចត្រូវសងអ្វីមួយ ដូចជាប្រាក់ខ្ចី ប្រាក់ឈ្នួល ប្រាក់ទូទាត់ការទិញទំនិញ ឬសេវា អោយដល់សហគ្រាស ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស ឱ្យប្រគល់សំណងនោះដល់នាយកដ្ឋានពន្ធដារ ទោះជាសាច់ប្រាក់ ឬជាវត្ថុក្តី ក្នុងចំនួនដែលមានតំលៃមិនលើសពីចំនួនប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ការប្រាក់ និងចំណាយក្នុងការប្រមូលពន្ធ ។

២- ការចេញលិខិតជូនដំណឹងទៅជូនអាជ្ញាធរមានសមត្ថកិច្ច ស្នើសុំឱ្យទុកជាមោឃៈ ឬព្យួរទុកនូវលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណផ្សេងៗ ដែលអនុញ្ញាតឱ្យសហគ្រាស ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករ

សហគ្រាសអនុវត្តសកម្មភាពណាមួយ ជាអាទិ៍មាន សកម្មភាពលទ្ធកម្ម ជួលទ្រព្យសម្បត្តិ គំរោងវិនិយោគ ការចុះបញ្ជីពាណិជ្ជកម្ម... ជាដើម ។

៣- ការបញ្ឈប់ប្រតិបត្តិការនាំចេញ នាំចូល សំដៅដល់ការឃាត់ទុកទំនិញដែលជារបស់សហគ្រាស ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងដែលស្ថិតនៅក្រោមការគ្រប់គ្រង របស់ទីចាត់ការគយ និងរដ្ឋាករ និងការលក់ទំនិញទាំងនោះ បើសិនមានការចាំបាច់ក្នុងបរិមាណដែល មានតំលៃមិនលើសពីប្រាក់ពន្ធ ប្រាក់បន្ថែម ការប្រាក់ និងចំណាយក្នុងការប្រមូលពន្ធ ។

៤- ការឃាត់ទុកគណនីនៅធនាគាររបស់សហគ្រាស ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងការតម្រូវឱ្យធនាគារប្រគល់ឱ្យនាយកដ្ឋានពន្ធដារនូវប្រាក់ក្នុងគណនីរបស់សហគ្រាស ឬរបស់អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករ ទាំងនោះក្នុងចំនួនដែលមិនលើសពីចំនួនទឹកប្រាក់សំរាប់ទូទាត់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ការប្រាក់ និង ចំណាយក្នុងការប្រមូលពន្ធ ។

៥- ការរឹបអូស ការលក់ទ្រព្យសម្បត្តិរបស់សហគ្រាស ឬអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសក្នុងចំនួនដែលមានតំលៃគ្រប់គ្រាន់សំរាប់ទូទាត់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ការប្រាក់ តាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ និងចំណាយក្នុងការប្រមូលពន្ធ ទោះបីជាទ្រព្យសម្បត្តិត្រូវបានកាន់កាប់ដោយបុគ្គលខ្លួនឯង ឬដោយតតិយជនក្តី ។

**ប្រការ ៥.-** នីតិវិធី និងបែបបទនៃការអនុវត្តន៍វិធានការតឹងទារ ដូចមានចែងក្នុងប្រការ ៤ ខាងលើ ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍វិធានការតឹងទារបំណុលពន្ធលេខ ០៧៤ ប្រ.កសហវ.ពដ ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ១៩៩៨ ។

**ប្រការ ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៥

**គាត ឈន់**

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ